Michiel Pestman **មេធាវីការពារ នួន ជា**

**សេចក្តីថ្លែងការបើកឆ្លើយតបនឹងសហព្រះរាជអាជ្ញា**

ថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ដំរីងាប់យកចង្អេរបាំង**

តើហេតុអ្វីបាជាខ្ញុំនៅទីនេះ?

ខ្ញុំបានសួរខ្លួនខ្ញុំ នូវសំណួរដូចនេះជាច្រើនដងចាប់តាំងពីពេលដែលខ្ញុំមកដល់ប្រទេសកម្ពុជា ដែលគិតមកដល់ពេលនេះជិតបួនឆ្នាំទៅហើយ។ ហើយខ្ញុំនឹងសួរសំណួរនេះម្តងទៀតនៅថ្ងៃនេះ។

ហេតុផលដែលសំខាន់ដែលធ្វើឱ្យខ្ញុំមកទីនេះគឺច្បាស់ថា ខ្ញុំមកទីនេះ គឺតំណាងកូនក្តីរបស់ខ្ញុំដើម្បីនិយាយ និងធ្វើរឿងរ៉ាវដែលប្រជាជនភាគច្រើនមិនអាចធ្វើ។

ខ្ញុំនឹងមិនរិះគន់ពាក្យសំដីរបស់ខ្ញុំ ឬដាក់ព្រំដែនអរូបិយមកលើខ្លួនខ្ញុំនោះទេ។ ហើយខ្ញុំសង្ឃឹមថា អ្នកនឹងក៏មិនធ្វើដូចនោះដែរ បើទោះជាការប៉ុនប៉ងធ្វើដូចនោះអាចមិនអាចទប់ទល់បានក៏ដោយ។

នៅក្នុងច្បាប់កម្ពុជាមានព្រំដែនច្បាប់សម្រាប់ឱ្យយើងគោរពតាម ក៏ប៉ុន្តែគួរឱ្យសោកស្តាយព្រំដែននៅ អវតក គឺត្រូវបានបង្កើតឡើងដោយឥទ្ធិពលនយោបាយ។

ខ្ញុំនៅទីនេះគឺដើម្បីនិយាយពីដំរីមួយ ឬដំរីជាច្រើននៅក្នុងបន្ទប់នេះ គឺដំរីដែលគ្មានអ្នកណាហ៊ាននិយាយ។

ក្នុងសំណុំរឿងនេះ តុលាការរងគ្រោះយ៉ាងហោចណាស់ក៏ដោយសារកំហុសបួនសំខាន់ គឺកំហុសដែលបុគ្គលដែលពាក់ព័ន្ធជាច្រើនមិនបានចូលរួម ក៏ប៉ុន្តែថែមទាំងធ្វើមិនដឹងមិនលឺទៀត។ ប៉ុន្តែដំរីទាំងនោះ នៅទីនោះ ហើយពួកគេគឺជាចំណុចដ៏អាក្រក់មួយ ហើយធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សំណុំរឿងនេះ និងអនាគតរបស់ អវតក ដែលជាស្ថាប័នយុត្តិធម៌ មិនមែនតាមបែបកម្ពុជា ក៏ប៉ុន្តែលក្ខណៈ“អន្តរជាតិ” ដែលត្រូវប្រកាន់យកបទដ្ឋានសិទ្ធិស្មើគ្នា។

នេះគឺជាអ្វីដែលលោក នួន ជា ចង់បានបំផុត និងមិនមែនអន់ជាងអ្វីដែលគាត់សមនឹងទទួលបាននោះទេ។

ខ្ញុំនឹងចាប់ផ្តើមនិយាយពីជំរឹតូចៗសិន ហើយបន្តទៅជំរឹធំៗ ដែលក្នុងគំនិតរបស់ខ្ញុំគឺជាជំរឹគម្រាមកំហែងបំផុតដល់តុលាការនេះ។

**ជំរឹទី ១៖ តុលាការ Nuremberg តូច**

តុលាការនេះត្រូវបានគេហៅថា តុលាការប្រវត្តិសាស្ត្រ គឺមិនខុសគ្នាទៅនឹងតុលាការធំបំផុតចាប់តាំងពី Nuremberg នោះទេ។ ខ្ញុំជឿជាក់ថា វាជាសំដីរបស់របស់ព្រះរាជអាជ្ញា គឺដូចគ្នានឹងព្រះរាជអាជ្ញា កំពុងតែរត់សម្រាប់តំណែងព្រះរាជអាជ្ញានៅ ICC។

ខ្ញុំគិតថា ប្រជាជនកម្ពុជា ជនរងគ្រោះត្រូវការការពិត។ សេចក្តីសម្រេចបំបែកកិច្ចដំណើរការរបស់លោកលោកស្រីចៅក្រមបានធ្វើឲ្យប៉ះពាល់ដល់បំណងរបស់ព្រះរាជអាជ្ញា និងតុលាការនេះ។

បន្ទាប់ពីតុលាការតូចនេះពិភាក្សាអំពីការជម្លៀសចេញពីទីក្រុងភ្នំពេញ លោក នួន ជា នឹងត្រូវបានដាក់ទោស និងឃុំឃាំង ហើយដោយគ្មានមន្ទិលសង្ស័យទេថា នឹងដាក់គុកគាត់អស់មួយជីវិត។ លោក នួន ជា បានដឹងជាមុនហើយថា តុលាការនេះនឹងដាក់ទោសគាត់ បើទោះជាមានភស្តុតាងមិនគ្រប់គ្រាន់ប្រឆាំងមកលើរូបគាត់ក្តី។

វានឹងមិន “ចាំបាច់” មាន និងមានបំណងតិចតួចសម្រាប់តុលាការតូចទីពីរ ឬក៏ទីបីទៀតទេ។ ខ្ញុំគ្មានទំនុកចិត្តថា សហគមន៍អន្តរជាតិ នឹងមានបំណងចំណាយ១៥០លានដុល្លាទៅលើការបន្តរដែលចំណាយដ៏ច្រើនហួសហេតុនោះទេ។ ហើយរដ្ឋាភិបាលកម្ពុជាវិញ និងសប្បាយចិត្តនៅពេលឃើញតុលាការនេះចប់ ដោយសារតុលាការនេះបន្តគម្រាមកំហែងធ្វើឲ្យប៉ះពាល់ដល់ខ្លួន។

សម្រាប់រដ្ឋាភិបាលកម្ពុជា ការចោទប្រកាន់ផ្សេងទៀត ការបោសសម្អាតផ្ទៃក្នុង ការកាប់សម្លាប់នៅភូមិភាគបូព៌ា បទល្មើសដែលកើតឡើងក្នុងជម្លោះព្រំដែនជាមួយវៀតណាម គឺជារឿងដែលគ្រោះថ្នាក់ ដោយសារការស៊ើបអង្កេតដ៏ហ្មត់ចត់មួយលើការចោទប្រកាន់នេះ នឹងនាំឲ្យមានការពាក់ព័ន្ធជាមួយមន្ត្រីសំខាន់ៗរបស់រដ្ឋាភិបាល។

ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន អ្នកទាំងអស់នេះក៏មានការចូលរួមទទួលខុសត្រូវផងដែរ។

លោក នួន ជា នឹងមិនត្រូវបានកាត់ទោសពីឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ មន្ទីរសន្តិសុខ ជំរុំកាងារ ការបោសសម្អាតផ្ទៃក្នុង ឬក៏រឿង ស២១នោះទេ។ តុលាការនេះគួរប្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត និងអ្នករង់ចាំសវនាការថា ឱកាសរបស់គាត់នឹងមិនអាចមាននោះទេ។

នៅក្នុងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់ខ្លួន សហព្រះរាជអាជ្ញាបានរៀបរាប់ពីការចោទប្រកាន់ជាច្រើន បានលើកឡើងពីឧក្រិដ្ឋកម្មដែលធ្វើឡើងដោយលោក នួន ជា និងជនជាប់ចោទដទៃទៀត។ ក៏ប៉ុន្តែ យើងខ្ញុំ និងលោកលោកស្រីចៅក្រម ដឹងថា នេះគ្រាន់តែជាវាំងននបាំងបង្អួចតែប៉ុណ្ណោះ។

អ្វីដែល លោក លោកស្រីចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងអាចធ្វើបាននោះ គឺទទួលស្គាល់ថា មានប្រជាជនជាច្រើន ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលពិពណ៌នាដោយសហព្រះរាជអាជ្ញា នឹងត្រូវបានធ្វើឲ្យខកចិត្តយ៉ាងខ្លាំង។

តុលាការនេះ នឹងគ្រាន់តែមានឈ្មោះថា ជាតុលាកាប្រវត្តិសាស្ត្រតែប៉ុណ្ណោះ។
នេះនឹងមិនមែនជាតុលាការសម្រាប់ប្រវត្តិសាស្ត្ររបបខ្មែរក្រហមនោះទេ ប៉ុន្តែជាតុលាការសម្រាប់តែពេលពីរបីថ្ងៃបន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានជម្លៀសតែប៉ុណ្ណោះ។

យ៉ាងហោចណាស់នេះនឹងជាតុលាកាតូចធំបំផុតចាប់តាំងពី Nuremberg។

**ដំរីទី ២៖ រឿងរ៉ាវចោះៗ**
ដំរីទីពីរគឺទាក់ទងនឹងដំរីទីមួយដែរ។

ដូចដែលបាននិយាយមកហើយថា តុលាការនេះនឹងមិនបង្កើតប្រវត្តិសាស្ត្រខ្មែរក្រហមឡើងវិញទេ ហើយក៏មិនលាតត្រដាងការពិតអំពីអ្វីដែលបានកើតឡើងក្នុងប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជាដែរ។

តុលាការនេះនឹងថែមទាំងមិនផ្តល់នូវរឿងរ៉ាវត្រឹមត្រូវស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការជម្លៀសបន្ទាប់មកទៀតនោះទេ។ នេះជាតុលាការតូចមួយដែលកាត់តែរឿងចោះៗ។

តុលាការនឹងដូចជារឿងល្ខោន ឬក៏ខ្សែភាពយន្ត ដែលមានតួអង្គមិនគ្រប់គ្រាន់ ជាតួសម្តែងតូច។ តួសម្តែងសំខាន់ៗ នឹងអត់មានវត្តមាន។ ហើយលទ្ធផល គឺជារឿងរ៉ាវចោះៗតែប៉ុណ្ណោះ។

តើ Kissinger នៅឯណា?

Kissinger គឺជាអ្នកធ្វើឲ្យមានការទម្លាក់គ្រាប់បែកលើទឹកដីកម្ពុជានៅចុងទសវត្សរ៍ឆ្នាំ៦០ និង ៧០។ មានប្រជាជនស្លូតត្រង់រាប់សែននាក់ស្លាប់ដោយសារការទម្លាក់គ្រាប់បែក។ អ្នកប្រវត្តិសាស្ត្រភាគច្រើនយល់ស្របថា បើពុំមានការទម្លាក់គ្រាប់បែកទេ ខ្មែរក្រហមនឹងប្រហែលជាមិនអាចកាន់អំណាច មិនអាចរំដោះទីក្រុងភ្នំពេញ និងមិនអាចជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងដោយសារតែការទម្លាក់គ្រាប់បែករបស់អាមេរិកនោះទេ។

បើគ្មាន Kissinger ក៏គ្មានតុលាការថ្ងៃនេះដែរ។

ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា គឺជាឧក្រិដ្ឋកម្មសង្គ្រាមយ៉ាងពិតប្រាកដ ដែល Kissinger ត្រូវតែបាននាំយកមកកាត់ទោស។ ប៉ុន្តែដោយសារដែនយុត្តាធិការរបស់តុលាការនេះ ជាអកុសលគឺមិនអាចឲ្យលោកលោកស្រីចៅក្រមនាំយកគាត់មកកាត់ទោសបានទេ ក៏ប៉ុន្តែក្នុងឋានៈជាសាក្សីគាត់អាច និងត្រូវតែដើរតួនាទីសំខាន់មួយ។

បញ្ហាសំខាន់នោះគឺថា លោកលោកស្រីមិនបានអនុញ្ញាតិឲ្យយើងខ្ញុំលើក និងពិភាក្សាពីតួនាទីរបស់តួអង្គផ្សេងទៀតក្នុងរឿងល្ខោននេះ។

ហេតុអ្វីបានជាគ្មានសាក្សីខាងក្នុងនៅក្នុងបញ្ជីសាក្សី?
តើ ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន និងមន្ត្រីរដ្ឋាភិបាលមួយចំនួនទៀតដែលដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅឯណា?

វាមិនមែនដោយសារយើងមិនបានស្នើសុំឲ្យគាត់ចូលមកទេ ឬក៏គាត់គ្មានអ្វីសំខាន់នោះទេ។ តែផ្ទុយពីនេះយើងគិតថា សក្ខីកម្មរបស់គាត់នឹងមានសារសំខាន់ក្នុងការយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ហេង សំរិន, ជា ស៊ីម និង ហ៊ុន សែន មានវត្តមានពេលនោះ ហើយមានតួនាទីសំខាន់។

សក្ខីកម្មរបស់គាត់នឹង ឬសំខាន់បំផុតសម្រាប់រកឲ្យឃើញថា តើ នួន ជា មានការទទួលខុសត្រូវលើបទចោទក្នុងដីកាចោទតូចនេះដែរឬក៏អត់។

ដូចដែលបានពន្យល់ ការសម្តែងនេះគឺមិនគ្រប់គ្រាន់ បើទោះក្នុងសវនាកាតូចដូចនេះក្តី។ ហើយខ្ញុំចង់បញ្ជាក់បន្ថែមថា នេះមិនមែនដោយសារការរិតត្បិតខាងច្បាប់ដាក់មកលើការងាររបស់លោកលោកស្រីដោយវិធានរបស់តុលាការនេះទេ។

លោកលោកស្រីបានបង្ហាញ "ការស្ទាក់ស្ទើរ" ដោយមិនស្រួលក្នុងការតទល់នឹងកម្លាំងនយោបាយក្នុងប្រទេសនេះ។

**ដំរីទី៣៖ ២ភាគ៥នៃតុលាការ**

ដំរីទី៣នេះគឺជាដំរីដែលយើងនិយាយប្រាប់អ្នកជាច្រើនលើកច្រើនសារមកហើយកាលពីលើកមុន។ វាគឺជាការបន្តជ្រៀតជ្រែករបស់រដ្ឋាភិបាលទៅក្នុងកិច្ចការរបស់ អវតក។ ប៉ុន្តែខ្ញុំគិតថាបញ្ហាវាធ្ងន់ធ្ងរជាងនេះទៅទៀត។ បញ្ហាគឺមិនគ្រាន់តែថារដ្ឋាភិបាលកម្ពុជាកំពុងជ្រៀតជ្រែកកិច្ចការតុលាការប៉ុណ្ណោះទេ ប៉ុន្តែការជ្រៀតជ្រែកនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់លោក នួន ជា ក្នុងការទទួលការជំនុំជម្រះដោយយុត្តិធម៌។

បញ្ហាប្រឈមដែលសំខាន់ជាងនេះទៀតនោះគឺថា អវតក *មិនមែន*ជាតុលាការការឯករាជ្យឡើយ។ តើនរណានឹងជួសជុសការខូចខាតសិទ្ធិរបស់លោក នួន ជា? តុលាការនេះទទួលរងនូវការវិនាសហិនហោចនៅពេលដែលសហាគមន៍អន្តរជាតិបានទទួលយកគំនិតមិនល្អក្នុងការដាក់ចៅក្រមកម្ពុជាភាគច្រើនក្នុងអង្គជំនុំជម្រះនៅ អវតក។

ដោយសារតែហេតុផលនេះហើយ អវតក មិនអាចធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក នួន ជា បានឡើយ ទោះបីជាមានការអនុវត្តនូវប្រព័ន្ធសម្លេងភាគច្រើនលើសលប់ក៏ដោយ។ យន្តការណ៍សម្លេងភាគច្រើនលើសលប់នេះ គឺជាការអនុវត្តដែលគ្មានដំណើរការល្អទៅមុខ និងជាវិរូបភាពផ្នែកច្បាប់ ដូចដែលសេចក្តីសម្រេចនៅពេលថ្មីៗនេះរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញយ៉ាងច្បាស់។

លោកចៅក្រមកម្ពុជាទាំងបីរូប លោកគឺជា និងធ្លាប់ជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា។ លោកមិនត្រូវបានជ្រើសរើសដោយសារតែភាពឯករាជ្យរបស់លោក ឬដោយសារតែចេតនាចង់ប្រឆាំងនិងផលប្រយោជន៍របស់រដ្ឋាភិបាលកម្ពុជា នៅពេលដែលអ្នកត្រូវបានរដ្ឋាភិបាលស្នើឲ្យធ្វើដូច្នេះឡើយ។

ផ្ទុយទៅវិញ ខ្ញុំខ្លាចតែលោកត្រូវបានគេជ្រើសរើសដើម្បីមកបំពេញកន្លែងដែលមានផាសុខភាពដោយសារតែភក្តីភាពរបស់លោកតែប៉ុណ្ណោះ។ លោកគឺជាអ្នកបម្រើដ៏គួរឲ្យទុកចិត្តរបស់រដ្ឋាភិបាលកម្ពុជា ហើយអ្នករាល់គ្នាក្នុងតុលាការនេះដឹងថាលោក នឹងមិនធ្វើសេចក្ដីសម្រេចណាមួយដែលប្រឆាំងនឹងផលប្រយោជន៍ខ្លួនឯងឡើយ។

ពិតណាស់នេះគឺជាមូលហេតុដែលលោក ហ៊ុន សែន បានយល់ព្រមដោយខ្លួនផ្ទាល់ក្នុងការចាត់តាំងអ្នកឲ្យមកធ្វើចៅក្រម ហើយដោយសារតែមូលហេតុនេះហើយទើបការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជាទៅក្នុងកិច្ចការតុលាការមានការកំណត់។ វាគ្មានមន្ទិលសង្ស័យអ្វីទៀតឡើយ ការណែនាំម្ដងម្កាលពីរដ្ឋាភិបាលកម្ពុជាគឺគ្រប់គ្រាន់ទៅហើយ។ អ្នកបម្រើដែលស្មោះត្រង់ដឹងថាពួកគេត្រូវធ្វើអ្វីខ្លះហើយ។

ចៅក្រម យូ ឧត្តរ៉ា លោកដឹងច្បាស់ណាស់ថាត្រូវធ្វើអ្វីខ្លះនៅពេលដែលលោកត្រូវបានគេផ្ដល់សេចក្ដីទុកចិត្តឲ្យចាត់ការរឿងបរិហាកេរ្តិ៍ប្រឆាំងលោកស្រី មូ សុខហួរ។ លោកដឹងពីអ្វីដែលលោកត្រូវធ្វើ ហើយលោកបានធ្វើវាក្នុងចំណោមការជំនុំជម្រះក្ដី ដ៏ចម្រូងចម្រាសមួយក្នុងចំណោមការជំនុំជម្រះដែលចម្រូងចម្រាសបំផុតជាច្រើនទៀតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជានៅពេលថ្មីៗនេះដែលទទួលរងការរិះគន់យ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិ។

វាជាការជំនុំជម្រះក្ដីតាមបែបឆាកល្ខោនដែលគ្មានការខ្មាសអៀនអ្វីទាំងអស់ ហើយលទ្ធផលគឺកើតចេញពីការបង្គាប់បញ្ជាខាងនយោបាយសុទ្ធសាធមិនមែនកើតឡើងដោយសារតែបទដ្ឋានជំនុំជម្រះក្ដីដោយយុត្តិធម៌ឡើយ។

ជាថ្នូរនឹងអ្វីដែលលោកបានធ្វើ ចៅក្រម យូ ឧត្តរ៉ា លោកត្រូវបានតំឡើងតំណែងឲ្យមកធ្វើជាចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង។ ក្នុងប្រទេសកម្ពុជាភក្ដីភាពតែងតែទទួលបាននៅការតបស្នងនៅពេលដែលភាពមិនស្មោះត្រង់តែងតែទទួលទណ្ឌកម្ម។

នេះគឺជាសត្វដំរីទី៣ ដែលជាកំហុសដ៏ធំមួយរបស់តុលាការនេះ។ យើងចង់បំភ្លេចបញ្ហានេះ ព្រោះការជ្រៀតជ្រែករបស់រដ្ឋាភិបាលគឺគ្រាន់តែជាបញ្ហាបន្ទាប់បន្សំតែប៉ុណ្ណោះ។ ថាតើរដ្ឋាភិបាលជ្រៀតជ្រែកចូលក្នុងកិច្ច

ការរបស់តុលាការឬអត់នោះគឺច្បាស់ជាមិនមែនជាបញ្ហាពិតប្រាកដឡើយព្រោះចៅក្រមដែលមានឯករាជ្យនឹងដឹងពីរបៀបដោះស្រាយជាមួយនឹងការជ្រៀតជ្រែកខុសច្បាប់បែបនេះនៅក្នុងបរិស្ថានតុលាការដែលមានកំពុងដំណើរការយ៉ាងត្រឹមត្រូវ។

ប៉ុន្តែជាអកុសល ករណីនេះមិនមែនជាតថភាពនៅ អវតក ឡើយ។ ការពិតគឺថាក្នុងនាមជាអ្នកដឹកនាំរដ្ឋាភិបាលកម្ពុជាមិនចាំបាច់ជ្រៀតជ្រែកទៅក្នុងកិច្ចការរបស់តុលាការនេះទេ ព្រោះតុលាការនេះ *គឺជា* រដ្ឋាភិបាលកម្ពុជា។ នេះជាតុលាការឯករាជ្យ២ភាគ៥។

ផ្ទុយទៅវិញ ការបែកចែកអំណាចដ៏ត្រឹមត្រូវ និងប្រព័ន្ធតុលាការឯករាជ្យពិតប្រាកដនៅកម្ពុជាគឺគ្រាន់តែជាការយល់ច្រឡំដ៏ធំមួយប៉ុណ្ណោះនៅក្នុងរដ្ឋាភិបាលបច្ចុប្បន្នដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។ ប្រជាជនកម្ពុជានៅតែកំពុងទន្ទឹងរង់ចាំអ្នកមកជួយសង្គ្រោះពួកគេ។

**ជំរើទី ៤៖ អ្នកភាគតិចនៅស្ងាត់ស្ងៀម**

នោះនាំខ្ញុំមកដល់ជំរើចុងក្រោយគឺ អ្នកភាគតិចនៅស្ងាត់ស្ងៀមក្នុងតុលាការនេះ។
បញ្ហាធំបំផុតរបស់តុលាការនេះ រហូតមកដល់ពេលនេះ គឺថាចៅក្រមអន្តរជាតិមិនព្រមប្រើអំណាចតិចតួចដែលលោកលោកស្រីមាន។ ការស្ងាត់ស្ងៀមរបស់លោកលោកស្រី ជាការគំរាមកំហែងធំបំផុតចំពោះយុត្តិធម៌។

ខ្ញុំយល់ថា តំណែងរបស់លោកលោកស្រីក្នុងតុលាការនេះមិនត្រូវច្រណែននោះទេ។
ជម្រើសរបស់លោកលោកស្រីមានកម្រិត។ កន្លងមក យើងគ្រាន់តែនិយាយមែនផងលេងសើចផងថា អ្នកចៅក្រមអន្តរជាតិ មានជម្រើស ២ គឺអ្នកអាចលាលែងឥឡូវនេះ ដូចចៅក្រមដទៃទៀត ដែលបានលាលែងរួចហើយមុនលោកលោកស្រី ឬលើកលែងទោស(ដល់ជនជាប់ចោទ)នៅចុងបញ្ចប់នៃការជំនុំជម្រះ។
ជម្រើសទាំងនេះជាជម្រើសហួសហេតុប៉ុន្តែខ្ញុំយល់ថាវាជាផ្លូវចេញតែមួយគត់ដែលមានកិត្តិយស។

អ្វីគ្រប់យ៉ាងក្នុងរវាងជម្រើសហួសហេតុនេះគឺជា ហើយនឹងក្លាយជាការបន្ទាបបន្ថោកដ៏អាក្រក់មួយដល់បទដ្ឋានអន្តរជាតិដែលអ្នកគួរអនុវត្ត និងការពារ។
ដូចដែលយើងបានអះអាងពីមុនរួចហើយ តុលាការនេះនឹងមិនក្លាយជាគំរូល្អសម្រាប់កម្ពុជានោះទេ។ វានឹងមិនបង្ហាញកម្ពុជាពីរបៀបធ្វើការជំនុំជម្រះត្រឹមត្រូវ និងយុត្តិធម៌ឡើយ ។

ជាការពិត អវតក គំរាមពីការត្រូវឆ្លងរោគនៅកម្ពុជា។

មិនត្រឹមតែមិនជួយប្រព័ន្ធច្បាប់កម្ពុជាឲ្យឈានដល់កម្រិតស្តង់ការអន្តរជាតិ និងឲ្យ អនុវត្តនីតិរដ្ឋប៉ុណ្ណោះទេ តែតុលាការនេះកំពុងធ្លាក់ចូលបន្តិចម្តងៗក្នុងភក់ជ្រំរបស់កម្ពុជាដែលនីតិរដ្ឋអនុវត្តត្រូវបានគេយកមកអនុវត្ត តែនៅពេលដែលមានប្រយោជន៍ដល់រដ្ឋាភិបាលតែប៉ុណ្ណោះ។

លោក នួន ជា ព្រួយបារម្ភថា បំណងរបស់អ្នកចង់ជួយសង្គ្រោះស្ថាប័ននេះកុំឲ្យបរាជ័យនឹងលប់លើតួនាទីរបស់អ្នកក្នុងការធានាសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។
គាត់ភ័យខ្លាច ហើយយើងក៏អញ្ចឹងដែរថា អ្នកនឹងចង់បានការជំនុំជម្រះដែលមិនសូវយុត្តិធម៌ ឬគ្មានយុត្តិធម៌ជាជាងគ្មានការជំនុំជម្រះ។

ការរកឃើញនាពេលថ្មីៗនេះ ដែលលោកស្រីចៅក្រម Cartwright រៀបចំកិច្ចប្រជុំរវាងភាគគីតែម្ខាងជាប្រចាំជាមួយនឹងព្រះរាជអាជ្ញា មិនបានជួយស្តារទំនុកចិត្តរបស់លោក នួន ជា ទៅលើភាគីអន្តរជាតិនៃតុលាការនេះឡើយ។

លោក នួន ជា យល់ឃើញថា ក្នុងអំឡុងកិច្ចប្រជុំទាំងនោះ បញ្ហាសំខាន់ៗជាច្រើន ត្រូវបានលើកមកពិភាក្សា បញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចជាបញ្ហាសំខាន់នៃការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិចំពោះការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជា។

លោក នួន ជា យល់ឃើញថា ចៅក្រមអន្តរជាតិ ក្នុងសាលាក្តីនេះ យ៉ាងហោចណាស់ ម្នាក់ក្នុងចំណោមពួកគេ បានសម្រេចក្នុងកិច្ចប្រជុំឯកជនជាមួយនឹងព្រះរាជអាជ្ញាថាការស៊ើបអង្កេតបែបនោះប្រហែលមិនមែនជាគំនិតល្អទេ ព្រោះវាមិនត្រឹមតែអាចគំរាមកំហែងសំណុំរឿង ០០៣ និង០០៤ ប៉ុណ្ណោះទេ តែថែមទាំងដល់សំណុំរឿង ០០២ ទៀតផង។

អ្វីដែលលោកលោកស្រីចៅក្រមអន្តរជាតិ គួរធ្វើ ឬគួរបានធ្វើរួចហើយ គឺ ត្រូវនិយាយចេញមកក្រៅឲ្យគេដឹង។ និយាយចេញក្នុងនាមយុត្តិធម៌! មិនមែនតែក្នុងបន្ទប់បិទជិតនោះទេ គឺត្រូវនិយាយជាសាធារណៈ។

តើអ្នកនៅទីណា ពេលយើងជំទាស់ទៅនឹងភាពសាកសមរបស់ចៅក្រម និល ណុន ក្នុងការធ្វើជាប្រធានក្នុងការជំនុំជម្រះនេះ?

ចៅក្រម Cartwright និងចៅក្រម Lavergne: តើលោកលោកស្រី ពិតជាគិតថា ការសារភាពទទួលយកសំណូករបស់សហសេវិកលោកលោកស្រី មិនប៉ះពាល់ដល់ការធ្វើជាប្រធានក្នុងការជំនុំជម្រះនេះទេឬ? តើលោកលោកស្រីពិតជាលិចជ្រៅសែនជ្រៅហើយមែនទេ?

ខ្ញុំពិបាកនឹងជឿណាស់។ ប៉ុន្តែ ហេតុអ្វីពេលនោះអ្នកមិនជំទាស់?

តើវាដោយសារតែការជំទាស់បែបនេះនឹងបង្ហាញពីចំណុចខ្សោយនៃប្រព័ន្ធនេះឬ? តើនឹងមិនមែនជាមូលហេតុដែលអ្នកនៅទីនេះទេឬ?

ហើយតើអ្នកនៅឯណា ពេល អៀង ធីរិទ្ធ ចោទសួរពីឯករាជភាពរបស់ចៅក្រម យូ ឧត្តរ៉ា?

តើលោកលោកស្រីពិតជាគិតថា ចៅក្រមដែលមានប្រវត្តិមិនច្បាស់លាស់ ស័ក្តិសមធ្វើជាចៅក្រមក្នុងតុលាការនេះទេ?
ឬតើលោកលោកស្រីគិតថា ការជំទាស់នឹងមិនផ្លាស់ប្តូរអ្វីបានទេ ឬគ្រាន់តែធ្វើឲ្យជីវិតរបស់លោកលោកស្រីនៅសាលាក្តីនេះកាន់តែលំបាកថែមទៀតនៅពេលដែលទំនាក់ទំនងការងាររបស់លោកលោកស្រីនៅទីនោះវាផុយស្រួយរួចទៅហើយនោះ?

បើអញ្ចឹង យើងគិតថា លោកលោកស្រីធ្វើខុសហើយ។
ការដែល លោកលោកស្រីបាត់បង់ឱកាសរបស់លោកលោកស្រីក្នុងការបង្ហាញវត្តមានរបស់ខ្លួននៅតុលាការនេះ មិនមែនជាការបរាជ័យទាំងស្រុងនោះទេ។

ភាពស្ងាត់ស្ងៀមរបស់លោកស្រីចៅក្រម Cartwright និងចៅក្រម Lavergne កំពុងធ្វើឲ្យថ្លង់ហើយ។
វាគឺជាបរាជ័យរបស់សហគមន៍អន្តរជាតិក្នុងតុលាករនេះ ដែលបានបង្ខំអ្នកនាង សេង ធារី ដាក់លិខិតលាលែង(ពីដើមបណ្តឹងរដ្ឋប្បវេណី)កាលពីសប្តាហ៍មុន។
ពេលដើមបណ្តឹងរដ្ឋប្បវេណីនិងក្រុមការពារក្តីរកឃើញមូលហេតុរួម វាមានមូលហេតុធ្ងន់ធ្ងរដែលត្រូវបារម្ភ។

ការខកខានរបស់ចៅក្រមអន្តរជាតិក្នុងតុលាការនេះក្នុងការធ្វើអ្វីដែលពួកគេគួរធ្វើជាដំរីលេចផ្លោបំផុត និងចុងក្រោយក្នុងតុលាការនេះ។

រហូតមកល់ពេលនេះ មានតែចៅក្រមអន្តរជាតិក្នុងអង្គបុរេជំនុំជម្រះទេ ដែលបានបង្ហាញភាពក្លាហាន ប៉ុន្តែជាការសោកស្ដាយ ពុំមានប្រយោជន៍អ្វីច្រើននោះទេ។

## ត្អូកកំប្លែងតុលាការ

ខ្ញុំគិតថា តុលាការនេះត្រូវការត្អូកកំប្លែង។
ជាការឆ្លើយតបចំពោះសំណួរដែលខ្ញុំលើកឡើងពេលចាប់ផ្ដើម នោះជាមូលហេតុដែលខ្ញុំនៅទីនេះ។

វាជាតួនាទីខុសធម្មតាមួយ ជាតួនាទីដែលខ្ញុំមិនធ្លាប់ដើរ ប៉ុន្តែគេត្រូវលើកកញ្ចក់ឡើង និងបង្ហាញពីវិការៈគ្រឹះនៃតុលាការនេះ។

ជាការពិត តួនាទីរបស់ត្អូកកំប្លែងតុលាការជាតួនាទីមិនច្បាស់លាស់។
ជាមួយវត្តមានរបស់ខ្លួន ត្អូកកំប្លែងធ្វើឲ្យប្រព័ន្ធមានភាពស្របច្បាប់ និងធ្វើឲ្យគេចងចាំនូវប្រព័ន្ធដែលខ្លួនយកមកចំអកលេង។
ខ្ញុំដឹងថា វត្តមានរបស់ខ្ញុំនៅទីនេះ នឹងត្រូវយកទៅប្រើដោយអ្នកដទៃ សហគមន៍អន្តរជាតិ អង្គការសហប្រជាជាតិ ដើម្បីអះអាងថា នេះជាតុលាការដែលដំណើរការល្អ តែតាមពិតទៅវាមិនមែនទេ។

ប៉ុន្តែខ្ញុំមិនមែន Hope Stevens។
ហើយខ្ញុំមិនចង់ធ្វើជាគាត់ដែរ។

Hope Stevens ជាអ្នកបិទបាំងឆាកជំនុំជម្រះឆ្នាំ ១៩៧៩ ប្រឆាំងនឹងក្រុមប៉ុលពត និងអៀង សារី ដែលបានបង្កើតឡើងដោយអ្នកតែមួយ ដែលបង្កើតតុលាការនេះ។

Hope Stevens ជាមេធាវីដែលចាត់តាំងដើម្បីតំណាងក្រុមនេះ ដែលត្រូវបានជំនុំជម្រះដោយកំបាំងមុខ។

ក្នុងកិច្ចពិភាក្សាបិទការស្ដរដេញដោលដ៏រំជួលចិត្ត Hope Stevens មិនស្នើឲ្យលើកលែងទោសទេ ប៉ុន្តែស្នើសុំឲ្យកាត់ទោស ប៉ុល ពត និងអៀង សារី អ្នកដែលគាត់គួរការពារផលប្រយោជន៍របស់អ្នកទាំងពីរនេះ។

វត្តមានរបស់គាត់ និងអាកប្បកិរិយារបស់គាត់ ក្នុងអំឡុងពេលជំនុំជម្រះជាការខ្មាស់អៀនមួយចំពោះវិជ្ជាជីវៈរបស់ខ្ញុំ។

ខ្ញុំមិនធ្វើជាអ្នកបិទបាំងភាពអយុត្តិធម៌នៃតុលាការនេះទេ។
រាល់ថ្ងៃ ពេលខ្ញុំក្រោកពីដំណេក ប៉ុន្មានខែ ប៉ុន្មានឆ្នាំទៀត ខ្ញុំនឹងមើលកញ្ចក់ និងសួរខ្លួនឯងនូវសំណួរសំខាន់ទាំងនេះ៖
តើតួកកំប្លែងតុលាការអស់រឿងកំប្លែងឬនៅ?
តើអ្នករាល់គ្នាចុងបញ្ចប់ឈប់សើចហើយឬ?

តើការជំនុំជម្រះនេះគឺគ្រាន់តែជាការជំនុំជម្រះឡើងវិញនូវការជំនុំជម្រះក្តីតាមបែបឆាកល្ខោនកាលពីឆ្នាំ ១៩៧៩ ដូចអ្វីដែល សេង ធារី ជឿជាក់ឬ?

ប្រសិនបើមែន ខ្ញុំនឹងដោះអាវថៅក្រមរបស់ខ្ញុំចេះ ហើយទៅនៅជាមួយ នួន ជា ក្នុងមន្ទីឃុំឃាំងដែលនៅទីនោះខ្ញុំនឹងអាចតាមដាន ហើយប្រហែលជារីករាយនឹងទស្សនាឆាកល្ខោននេះលើកញ្ចក់ទូរទស្សន៍យ៉ាងសប្បាយផងដែរ៕